ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy

លេខ: ០៧៤១ រ៉ែ.បល.លណន

# បទប្បញ្ញត្តិ និង ការម្រិតវិន័យ
# ចំពោះបេក្ខជនដែលប្រព្រឹត្តខុសឆ្គង នៅពេលប្រឡងប្រជែង
# ចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងរ៉ែ និង ថាមពល សម្រាប់ឆ្នាំ២០១៨

## ១. បទប្បញ្ញត្តិ

*ក/ ត្រូវបានកំណត់ថាមានបំណងលួចចម្លង ចំពោះការប្រព្រឹត្តនូវសកម្មភាពដូចខាងក្រោមៈ*

- យកជាប់នឹងខ្លួន នូវសៀវភៅ ឬសំណៅឯកសារផ្សេងៗចូលក្នុងមណ្ឌលប្រឡង
- លាក់ជាប់នឹងខ្លួន នូវសៀវភៅ ឯកសារ ឬសំណៅឯកសារ ឬទូរស័ព្ទដៃ និង ឧបករណ៍អេឡិចត្រូនិកគ្រប់ប្រភេទ
- ការចូលក្នុងបន្ទប់ប្រឡងមុនគេ ដើម្បីចម្លងមេរៀនទុក នៅថតតុដែលសាមីខ្លួនអង្គុយ។

*ខ/ ត្រូវទុកជាការលួចចម្លង ចំពោះការប្រព្រឹត្តនូវសកម្មភាពដូចខាងក្រោមៈ*

- សរសេរលើបាតដៃ លើភ្លៅ នឹងទ្រនាប់ជើង លើកន្សែងជូតមុខជាអាទិ៍ នៅក្នុងបន្ទប់ប្រឡង
- ចម្លងសំណៅកិច្ចការពីអ្នកដទៃ ឬ យកកិច្ចការអ្នកដទៃមកដាក់នៅកន្លែងដែលខ្លួនអង្គុយ
- អើតមើលសន្លឹកកិច្ចការអ្នកដទៃ
- ប្រើប្រាស់ទូរស័ព្ទដៃ និង ឧបករណ៍អេឡិចត្រូនិកគ្រប់ប្រភេទ នៅក្នុងបន្ទប់ប្រឡង
- អង្គុយខុសពីលេខតុរបស់ខ្លួន ដោយគ្មានការអនុញ្ញាតពីអនុរក្ស ឬ រំកិលមកអង្គុយកៀកអ្នកដទៃ
- រំកិលតុមកអង្គុយជាប់គ្នាខុសពីប្លង់កំណត់ដោយគណៈមេប្រយោគ
- ការចម្លងពីសំណៅ ឬឯកសារផ្សេងៗ
- ការដូរក្រដាសវិញ្ញាសា ដើម្បីឱ្យអ្នកដទៃជួយកែឱ្យ
- ការស្នើដល់អ្នកដទៃឱ្យជួយពន្យល់
- បង្កលក្ខណៈឱ្យអ្នកដទៃចម្លង។

## ២. ការម្រិតវិន័យ

រាល់បំណងលួចចម្លង និង ការលួចចម្លងជាក់ស្តែងត្រូវទទួលរងការពិន័យដូចខាងក្រោមៈ

- ការព្រមានពីមេប្រយោគប្រឡង និង ការដកហូតឯកសារ។
- ការបញ្ឈប់មិនឱ្យប្រឡងជាបន្ទាន់ ក្នុងសម័យប្រឡងដែលកំពុងប្រព្រឹត្តទៅ ក្រោយពីបេក្ខជនបានទទួលការណែនាំ ឬ ការព្រមាន និងត្រូវបានដកហូតយកឯកសារចេញ ដោយអនុរក្សប្រចាំបន្ទប់រួចហើយ តែបេក្ខជននោះនៅតែប្រព្រឹត្តកំហុសបន្តទៀត។

កម្រិតពិន័យនឹងត្រូវបានកំណត់ដោយគណៈមេប្រយោគ យោងតាមកំហុសជាក់ស្តែង។

បេក្ខជន ដែលធ្វើការគំរាមកំហែងទៅលើគណៈមេប្រយោគ ដែលបានដកហូតឯកសារដាក់ពិន័យផ្សេងៗ ឬ បេក្ខជនដែលធ្វើឱ្យប៉ះពាល់ដល់កិត្តិយស ឬ រូបរាងកាយដែលមានភាពជាក់ស្តែងនៅក្នុងបន្ទប់ប្រឡង ឬ នៅក្នុងមណ្ឌលប្រឡង ត្រូវបញ្ឈប់មិនឱ្យប្រឡងជាបន្ទាន់ ហើយប្រឈមមុខតាមផ្លូវច្បាប់ជាធរមាន។

ថ្ងៃអង្គារ ១រោច ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០១៨

**ជ.គណៈកម្មការប្រឡងប្រជែង**

**ប្រធាន**

**ឆិត លីនដា**